ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ៨.៣.០.៧.៥.៧ គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៦... ខែ៣... ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ កោះកុង មណ្ឌលគិរី រតនៈគិរី ព្រៃវែង ពោធិ៍សាត់ សៀមរាប ត្បូងឃ្មុំ ស្វាយរៀង កំពត ក្រចេះ និងខេត្តប៉ៃលិន**

**កម្មវត្ថុ** ៖ អំពីការបញ្ចូលផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ) ទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់ និងការរៀបចំបង្កើតគណៈកម្មាធិការផែនការគណនេយ្យភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ សម្រាប់ការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ។

**យោង** ៖ ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូនឯកឧត្តមជ្រាបថា៖ ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៦-២០១៨ ត្រូវបានអនុម័តដាក់ឲ្យអនុវត្ត កាលពីខែកុម្ភៈ ឆ្នាំ២០១៦។ ក្នុងផែនការអនុវត្តនេះ មានបែងចែកជាបួនសមាសភាគ និងតម្រូវឲ្យមានការអនុវត្តរួមគ្នានៅតាមស្រុកគោលដៅនីមួយៗ រវាងផ្នែកផ្គត់ផ្គង់(រាជរដ្ឋាភិបាល) និងផ្នែកតម្រូវការ (ប្រជាពលរដ្ឋតាមរយៈអង្គការសង្គមស៊ីវិល) ដែលផ្នែកផ្គត់ផ្គង់ត្រូវទទួលខុសត្រូវចំបងលើសមាសភាគទី១ (ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា) ចំណែកឯផ្នែកតម្រូវការទទួលខុសត្រូវចំបងលើសមាសភាគទី២ (ស្តីពីការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ)។ នៅចុងបញ្ចប់នៃដំណើរការអនុវត្តសកម្មភាពក្នុងសមាសភាគទី២ ទាំងសហគមន៍ឬអ្នកប្រើប្រាស់សេវា(ប្រជាពលរដ្ឋ) និងអង្គភាពផ្តល់សេវា (រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា) ត្រូវរៀបចំផែនការសកម្មភាពព្រមព្រៀងគ្នាមួយ ហៅថា "***ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ)***" ដែលផែនការសកម្មភាពនោះ ត្រូវមានការព្រមព្រៀងពីបណ្តាអ្នកពាក់ព័ន្ធក្នុងដំណើរការនៃកិច្ចប្រជុំរួមគ្នា។ ផ្អែកតាមគោលការណ៍ដែលបានកំណត់ក្នុងផែនការអនុវត្តគណនេយ្យភាពសង្គម បន្ទាប់ពីរៀបចំរួចរាល់ផ.ស.រ.គនេះ តម្រូវឲ្យមានការដាក់បញ្ចូលទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំសង្កាត់។

ដើម្បីធានាបាននូវនិរន្តភាពក្នុងការអនុវត្តនៅមូលដ្ឋាន ផែនការអនុវត្តគណនេយ្យភាពសង្គមបានចង្អុលបង្ហាញផងដែរនូវយន្តការសម្រាប់ការត្រួតពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ដោយបានកំណត់ឲ្យឃុំនីមួយៗត្រូវរៀបចំបង្កើតគណៈកម្មាធិការរួមមួយហៅថា "***គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម***" ដែលមានសមាសភាពមកពី អង្គភាពផ្តល់សេវា មានរដ្ឋបាលឃុំ មណ្ឌលសុខភាព សាលាបឋមសិក្សា តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។

អាស្រ័យហេតុនេះ សូមឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត មេត្តាជ្រាប និងជូនដំណឹងឲ្យដល់ក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅពិនិត្យ ពិចារណាដាក់បញ្ចូលផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគឃុំ និងរៀបចំបង្កើតគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាព សង្គមដូចមានក្នុងឯកសារជំនួយស្មារតីជូនភ្ជាប់មកជាមួយតាមការគួរ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
**អនុប្រធានប្រតិបត្តិ**

**ចាន់ ជារិន**

ចម្លងជូន៖
- រដ្ឋបាលខេត្ត ស្រុក និងឃុំគោលដៅ
- អង្គការ CARE, Save the Children, RACHA
- អង្គការ World Vision និងអង្គការ Star Kampuchea "ដើម្បីសហការអនុវត្ត"
- ឯកសារកាលប្បវត្តិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ........................./គ.ជ.អ.ប

*រាជធានីភ្នំពេញ, ថ្ងៃទី២៩.. ខែ..កញ្ញា. ឆ្នាំ២០១៦.*

# ឯកសារជំនួយស្មារតី
# ស្តីពី
# ការបញ្ចូលផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ) នៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់ និងការរៀបចំបង្កើតគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់សម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម

ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦-២០១៨ ត្រូវបានអនុម័ត ដាក់ឲ្យអនុវត្ត កាលពីខែកុម្ភៈ ឆ្នាំ២០១៦។ ក្នុងផែនការអនុវត្តនេះ មានបែងចែកជាបួនសមាសភាគ និងតម្រូវឲ្យមានការអនុវត្តរួមគ្នានៅតាមស្រុកគោលដៅនីមួយៗ រវាងផ្នែកផ្គត់ផ្គង់(រាជរដ្ឋាភិបាល) និងផ្នែកតម្រូវការ (ប្រជាពលរដ្ឋតាមរយៈអង្គការសង្គមស៊ីវិល) ដែលផ្នែកផ្គត់ផ្គង់ត្រូវទទួលខុសត្រូវចំបងលើសមាសភាគទី១ (ភាពងាយទទួលបានព័ត៌មាន នានា និងព័ត៌មានថវិកា) ចំណែកឯផ្នែកតម្រូវការទទួលខុសត្រូវចំបងលើសមាសភាគទី២ (ស្តីពីការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ)។ នៅចុងបញ្ចប់នៃដំណើរការអនុវត្តសកម្មភាពក្នុងសមាសភាគទី២ ទាំងសហគមន៍ឬអ្នកប្រើប្រាស់សេវា(ប្រជាពលរដ្ឋ) និងអង្គភាពផ្តល់សេវា (រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា) ត្រូវរៀបចំផែនការសកម្មភាពព្រមពៀងគ្នាមួយ ហៅថា "***ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ)***" ដែលផែនការសកម្មភាពនោះ ត្រូវឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងក្នុងដំណើរការរៀបចំប័ណ្ណដាក់ពិន្ទុដោយភ្នាក់ងារផ្តល់សេវា(វាយតម្លៃខ្លួនឯង) និងដោយប្រជាពលរដ្ឋ ព្រមទាំងមានការព្រមព្រៀងពីបណ្តាអ្នកពាក់ព័ន្ធក្នុងដំណើរការនៃកិច្ចប្រជុំរួមគ្នា។ ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ) នឹងរៀបរាប់អំពីអ្វីដែលប្រជាពលរដ្ឋ អ្នកផ្តល់សេវានៅមូលដ្ឋាន រដ្ឋបាលឃុំ និងការិយាល័យនានានៅថ្នាក់ស្រុកត្រូវធ្វើ ដើម្បីដោះស្រាយបញ្ហាខ្វះខាតដែលបានរកឃើញតាមរយៈសកម្មភាពតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ (ប័ណ្ណដាក់ពិន្ទុ)។ ផ្អែកតាមគោលការណ៍ដែលបានកំណត់ក្នុងផែនការអនុវត្តគណនេយ្យភាពសង្គម ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនេះ ត្រូវរៀបចំរួចរាល់ឲ្យបានមុនខែកញ្ញា ហើយដែលតម្រូវឲ្យមានការដាក់បញ្ចូលផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)នេះ ទៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ។

ដោយសារផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ត្រូវបានបង្កើត និងរៀបចំឡើងដោយឆ្លងកាត់ដំណើរការនៃការស្វែងរកបញ្ហា និងតម្រូវការតាមរយៈការប្រើប្រាស់ឧបករណ៍"ប័ណ្ណដាក់ពិន្ទុ" ទាំងភ្នាក់ងារផ្តល់សេវា(វាយតម្លៃខ្លួនឯង) និងដោយប្រជាពលរដ្ឋ ព្រមទាំងមានការពិភាក្សាចាត់អាទិភាពជាស្រេចលើសកម្មភាពដែលបានស្នើឡើងក្នុងកិច្ចប្រជុំរួមរបស់អង្គភាពផ្តល់សេវាទាំងបីនៅមូលដ្ឋាន។ ដើម្បីធានាថា សកម្មភាពជាអាទិភាពនានាទាំងនេះត្រូវបានយកចិត្តដាក់អនុវត្ត និងបានបញ្ចូលទៅក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវ

លេខាធិការដ្ឋាន



មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

ណែនាំឲ្យគណៈកម្មាធិការផែនការ និងថវិកា(គ.ផ.ថ) របស់ខ្លួនដាក់បញ្ចូលសកម្មភាពអាទិភាពនៃផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ទៅក្នុងកម្មវិធីវិនិយោគ ប្រចាំឆ្នាំរបស់ឃុំ សង្កាត់។

**ការដាក់បញ្ចូលនេះគណៈកម្មាធិការផែនការ និងថវិកាឃុំ សង្កាត់ (គ.ផ.ថ)ត្រូវ៖**

**១. បញ្ចូល ផ.ស.រ.គ ក្នុងតារាង ២.១ (បញ្ជីគម្រោងវិនិយោគដែលបានស្នើឡើង ) និងតារាង ២.២ (គម្រោងវិនិយោគជាអទិភាពប្រចាំឆ្នាំរបស់ឃុំ សង្កាត់)៖**

- សហការជាមួយគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ដើម្បីរៀបចំសកម្មភាពអាទិភាពដែលបានកំណត់ ទៅជាសំណើគម្រោងវិនិយោគ ដោយត្រូវកំណត់អំពីឈ្មោះគម្រោង ប្រភេទគម្រោង ទីតាំងគម្រោង តម្លៃប៉ាន់ស្មាន ទំហំលទ្ធផល និងអ្នកទទួលផល។
- ពិនិត្យ ផ្ទៀងផ្ទាត់ និងបន្សីគម្រោងអាទិភាព ជាមួយគម្រោងវិនិយោគដែលបានស្នើឡើង ដើម្បីចៀសវាងភាពត្រួតគ្នានៃសំណើគម្រោង។
- ស្រង់គម្រោងអាទិភាពនេះ បញ្ចូលក្នុងតារាងបញ្ជីគម្រោងវិនិយោគដែលបានស្នើ (តារាង ២.១) តាមផ្នែកនីមួយៗឲ្យបានសមស្រប មុននឹងចាត់អាទិភាពគម្រោងសំណើ(តារាង ២.២) សម្រាប់បង្ហាញនៅក្នុងសិក្ខាសាលាសមារណកម្មកម្មវិធីវិនិយោគនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

**២. បញ្ចូល ផ.ស.រ.គ ក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក (ជំហានទី៣)៖**

- បង្ហាញផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមក្នុងសិក្ខាសាលាសមាហរណកម្ម ដោយបញ្ជាក់អ្នកចូលរួមច្បាស់ថាមានចំនួនគម្រោងប៉ុន្មានជាគម្រោងបានមកពីផ.ស.រ.គ។
- ក្នុងករណីដែលសកម្មភាពនៅក្នុងផ.ស.រ.គ ពុំបានបញ្ចូលក្នុងជំហានទី២នៃដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់ ទាន់ពេលវេលា គ.ផ.ថ ត្រូវបង្ហាញបន្ថែមនូវលទ្ធផល ផ.ស.រ.គ នេះក្នុងផែនការសមាហរណកម្មថ្នាក់ស្រុក។

**៣. ការបញ្ចូល ផ.ស.រ.គ ក្នុងបញ្ជីគម្រោង និងសៀវភៅកម្មវិធីវិនិយោគឃុំ សង្កាត់៖**

- បន្ទាប់ពីសិក្ខាសាលាសមាហរណកម្ម ឃុំ សង្កាត់ត្រូវចាប់ផ្តើមរៀបចំជំហានទី៤(ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់)។ ដូចនេះគម្រោងដែលចេញពីផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនឹងត្រូវបន្តបញ្ចូលទៅតាមដំណើរការនានានៃជំហានទី៤ ដូចជា ការរៀបចំតារាងថវិកាវិនិយោគតាមប្រភព ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់មូលនិធិឃុំ សង្កាត់ការរៀបចំកាលវិភាគផ្សព្វផ្សាយ និងការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ល។

ក្នុងករណីដែលគម្រោងវិនិយោគពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមទាំងនេះ ត្រូវបានចាត់អាទិភាព និងទទួលបានការគាំទ្រថវិកាសម្រាប់អនុវត្ត មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងអនុវត្តគម្រោងទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពសក្តិសិទ្ធិ។

ដើម្បីធានាបាននូវនិរន្តភាពក្នុងការអនុវត្តនៅមូលដ្ឋាន ផែនការអនុវត្តគណនេយ្យភាពសង្គមបានចង្អុលបង្ហាញផងដែរនូវយន្តការសម្រាប់ការត្រួតពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដោយបានកំណត់ឲ្យឃុំ សង្កាត់នីមួយៗត្រូវរៀបចំបង្កើតគណៈកម្មាធិការរួមមួយហៅថា "***គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម***" ដែលមានសមាសភាពមកពី អង្គភាពផ្តល់សេវា មាន រដ្ឋបាលឃុំ មណ្ឌលសុខភាព សាលាបឋមសិក្សា តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធ។

ការរៀបចំ និងការបង្កើត**គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម** ត្រូវផ្អែកតាមខ្លឹមសារដូចខាងក្រោម៖

**១.គោលបំណង**

គណៈកម្មាធិការ **ផ.ស.រ.គ** នេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីផ្តល់វេទិកាសម្រាប់កិច្ចពិភាក្សា និងធ្វើសេចក្តីសម្រេចចិត្តលើការរៀបចំ ត្រួតពិនិត្យ និងតាមដានការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម តាមរយៈកិច្ចប្រជុំជាទៀតទាត់របស់ខ្លួន។

**២. គណៈកម្មាធិការ ផ.ស.រ.គ មានសមាសភាពដូចខាងក្រោម៖**

| | |
|---|---|
| ▪ មេឃុំ ចៅសង្កាត់ | ជាប្រធាន |
| ▪ ជំទប់ទី២ ចៅសង្កាត់រងទី២ | ជាអនុប្រធាន |
| ▪ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | ជាសមាជិក |
| ▪ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | ជាសមាជិក |
| ▪ មន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់ | ជាសមាជិកអចិន្ត្រៃយ៍ |
| ▪ ស្មៀនឃុំ សង្កាត់ | ជាសមាជិក |
| ▪ ប្រធានឬអនុប្រធានមណ្ឌលសុខភាព | ជាសមាជិក |
| ▪ នាយក ឬនាយករងសាលាបឋមសិក្សា | ជាសមាជិក |
| ▪ តំណាងសហគមន៍ឬប្រជាពលរដ្ឋចំនួន (៣ទៅ៥ រូប) | ជាសមាជិក |
| ▪ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) | ជាសមាជិក |

ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងយុវវ័យ គណៈកម្មាធិការត្រូវមានសមាសភាពជាស្ត្រី២រូបយ៉ាងតិច និងតំណាងយុវជនម្នាក់។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍(CAF) ជាសមាជិកនៃគណៈកម្មាធិការអាចមានការប្រែប្រួលអាស្រ័យលើការព្រមព្រៀង និងសម្រេចរបស់មេឃុំ ចៅសង្កាត់។

**៣.តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការ ផ.ស.រ.គ**

គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម មានតួនាទី និងភារកិច្ចចំបងៗដូចខាងក្រោម៖

- បិតផ្សាយ និងផ្សព្វផ្សាយព័ត៌មានស្តីពីផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- សហការជាមួយអង្គការដៃគូអនុវត្តនៅមូលដ្ឋានក្នុងការរៀបចំការអនុវត្តដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (រួមទាំងការបញ្ចូលការវាយតម្លៃខ្លួនឯង)
- រៀបចំកិច្ចប្រជុំជាទៀងទាត់(១ខែម្តង) ដើម្បីពិភាក្សា និងត្រួតពិនិត្យការរីកចម្រើនការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម
- រៀបចំវេទិកាសាធារណៈដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីការរីកចម្រើននៃការអនុវត្តជូនប្រជាពលរដ្ឋ
- ធានាថាគម្រោងក្នុងផែនការសកម្មភាពរួមត្រូវបានស្រង់ និងបញ្ចូលក្នុងតារាងបញ្ជីគម្រោងវិនិយោគដែលបានស្នើក្នុងដំណើរការកសាងកម្មវិធីវិនិយោគឃុំ និងបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការអនុវត្ត**ផ.ស.រ.គ**ដាក់ជូនក្រុមប្រឹក្សាឃុំ ពិនិត្យ និងអនុម័ត
- ធានាថា**ផ.ស.រ.គ** ត្រូវបានបញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។
- កៀរគរធនធាន និងទំនាក់ទំនងជាមួយសប្បុរសជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងស្ថាប័ននានាដើម្បីលើកកម្ពស់ការគាំទ្រ**ផ.ស.រ.គ**។
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសកម្មភាពក្នុង**ផ.ស.រ.គ**

លេខាធិការដ្ឋាន

- ធានាឲ្យមានការរាយការណ៍អំពីការរីកចម្រើនជូនកិច្ចក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តកិច្ចការនានាផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទាក់ទងនឹងការងារគណនេយ្យភាពសង្គម។

**៤.តួនាទី និងភារកិច្ចរបស់សមាជិកនីមួយៗ៖**

**ក. ប្រធានគណៈកម្មាធិការ**

- ទទួលខុសត្រូវលើការងាររួមរបស់គណៈកម្មាធិការផ.ស.រ.គ
- ករណីប្រធានគណៈកម្មាធិការអវត្តមានត្រូវផ្ទេរសិទ្ធិទៅឲ្យអនុប្រធានជាអ្នកទទួលខុសត្រូវជំនួស
- ជាអធិបតីរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការផ.ស.រ.គ
- អញ្ជើញសមាជិកគណៈកម្មាធិការចូលរួមក្នុងគ្រប់ប្រជុំទៀងទាត់របស់គណៈកម្មាធិការ
- ដឹកនាំ និងចូលរួមជាមួយសមាជិកគណៈកម្មាធិការ ដើម្បីអនុវត្តសកម្មភាពនានា
- កៀរគរធនធានពីប្រភពនានាដើម្បីអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម
- ធានាឲ្យមានការដាក់បញ្ចូលផ.ស.រ.គ ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។
- ជំរុញ និងទាក់ទាញការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យវិភាជន៍ថវិកាវិនិយោគឃុំ សង្កាត់សម្រាប់គាំទ្រសកម្មភាពអាទិភាពក្នុងផ.ស.រ.គ។
- ធានាឲ្យមានរបាយការណ៍ទៀតទាត់ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម
- ធានាឲ្យមានកិច្ចសហការជាមួយអង្គការដៃគូអនុវត្តនៅមូលដ្ឋាន និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម។
- ធានាឲ្យមានកិច្ចសហការចូលរួមផ្តល់យោបល់ និងពិនិត្យសម្រេចក្នុងការជ្រើសរើសCAF

**ខ. អនុប្រធានគណៈកម្មាធិការ**

- ជំនួសប្រធាននៅពេលអវត្តមាន
- ចូលរួមប្រជុំក្នុងកិច្ចប្រជុំជាទៀងទាត់របស់គណៈកម្មាធិការផ.ស.រ.គ
- សហការ និងផ្តល់ការគាំទ្រដល់សមាជិកអចិន្ត្រៃយ៍
- បំពេញតួនាទី និងភារកិច្ចបន្ថែមតាមការប្រគល់ឲ្យពីប្រធានគណៈកម្មាធិការ

**គ. សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការ (មន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ឃុំ)**

- រៀបចំ និងចាត់ចែងការប្រជុំរបស់គណៈកម្មាធិការ
- ពិនិត្យ តាមដានការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម និងរាយការណ៍ជូនគណៈកម្មាធិការ
- បិទផ្សាយផ្ទាំងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (ព័ត៌មានទាក់ទងនឹងឃុំ សង្កាត់)
- សម្របសម្រួលការងារទូទៅជាមួយរដ្ឋបាលឃុំ សាលាបឋមសិក្សា និង មណ្ឌលសុខភាព
- ផ្តល់ការសហការជាមួយតំណាងអង្គការដៃគូអនុវត្តនៅមូលដ្ឋាន និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។
- ជួយមេឃុំ ចៅសង្កាត់ក្នុងដំណើរការតាមដានត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម និងរបាយការណ៍។
- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមដែលមេឃុំ ចៅសង្កាត់ ប្រគល់ជូន។
- គ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមនៅក្នុងឃុំ សង្កាត់។

**ឃ. សមាជិកនានារបស់គណៈកម្មាធិការ**

- ចូលរួមពិនិត្យ ពិភាក្សា និងឯកភាពលើការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម និងធ្វើសេចក្តីរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តតាមវិស័យរបស់ខ្លួន។
- ចូលរួមប្រជុំក្នុងកិច្ចប្រជុំជាទៀងទាត់របស់គណៈកម្មាធិការ

- ចូលរួមផ្តល់យោបល់ជូនគណៈកម្មាធិការ អំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គមនៅមូលដ្ឋាន។
- ផ្សព្វផ្សាយព័ត៌មានស្តីពីផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម និងព័ត៌មាននានារួមទាំងព័ត៌មានថវិកា ដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។
- លើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមក្នុងដំណើរការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម

**៥.របៀបរបបប្រជុំ៖**

គណៈកម្មាធិការត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់យ៉ាងតិច២ខែម្តង ដើម្បី៖

- ពិនិត្យ ពិភាក្សា និងអនុម័តលើផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម
- បញ្ចូលផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមទៅក្នុងផែនការវិនិយោគឃុំ សង្កាត់ក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ។
- កំណត់ការរីកចម្រើនដែលទទួលបាន និងការខ្វះចន្លោះក្នុងដំណើរការអនុវត្ត
- សម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមនានាក្នុងចំណោមតួអង្គអនុវត្តសំខាន់ៗ
- ត្រួតពិនិត្យ និងតាមដានការអនុវត្តផ.ស.រ.គ

គណៈកម្មាធិការអាចធ្វើការប្រជុំវិសាមញ្ញនៅពេលណាក៏បានតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការ។ ចំពោះសមាជិកដែលត្រូវអញ្ជើញចូលរួមប្រជុំអាស្រ័យទៅលើការសម្រេចរបស់ប្រធាន។

**៦.យន្តការគាំទ្រការអនុវត្ត៖**

- គណៈកម្មាធិការនេះ នឹងទទួលបានការគាំទ្របច្ចេកទេសពីមន្ត្រីបង្គោលគណនេយ្យភាពសង្គមថ្នាក់ស្រុក ឬថ្នាក់ខេត្ត។
- ចំពោះឃុំ សង្កាត់ដែលជាតំបន់គោលដៅថ្មីដែលអង្គការដៃគូអនុវត្តបានចាប់យក និងពង្រីកដើម្បីអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (អនុវត្តដំណើរការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ)អភិបាលខេត្ត អភិបាលស្រុកត្រូវសម្របសម្រួលគាំទ្រដល់ឃុំ សង្កាត់ក្នុងការរៀបចំបង្កើត និងធ្វើសកម្មភាពរបស់គណៈកម្មាធិការឲ្យបានស្របតាមឯកសារជំនួយស្មារតីនេះ។
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍(CAF)និងអង្គការដៃគូអនុវត្តនៅមូលដ្ឋានមានតួនាទីគាំទ្រគណៈកម្មាធិការនេះ និងគាំទ្រការតាមដាន និងការរាយការណ៍អំពីការអនុវត្តផ.ស.រ.គ។

-----❖-----